ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគិរី

~~~~~*~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
~~~~~

## សម្រេច

**មាត្រា១:** បង្កើតយន្តការចុះបញ្ជីសំណើវិនិយោគ ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅខេត្តរតនៈគីរី ដែលមានឈ្មោះថា **អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរី "អ.គ.វ.ខ.រគ"** និងដែលមានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| ១- អភិបាលខេត្ត | ប្រធាន |
| ២- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- អភិបាលរងទី១ខេត្ត | អនុប្រធាន |
| ៤- អភិបាលរងទី២ខេត្ត | អនុប្រធាន |
| ៥- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៧- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៨- ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ៩- ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១០- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១១- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- ប្រធានមន្ទីរផែនការ | សមាជិក |
| ១៣- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤- ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៥- ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៦- តំណាងសភាពាណិជ្ជកម្មខេត្ត | សមាជិកសង្កេតការណ៍ |
| ១៧- តំណាងលេខាធិការដ្ឋាន | លេខាធិការ |

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន ។

គ្រប់មន្ទីរ-អង្គភាពពាក់ព័ន្ធ-អភិបាលស្រុកក្នុងខេត្តរតនៈគីរី ដែលមិនមែនជាសមាជិករបស់អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរីនោះ នឹងត្រូវអញ្ជើញចូលរួមប្រជុំតាមករណីពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា២:**
- អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរី ត្រូវមានលេខាធិការដ្ឋានមួយ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍ នៃអនុគណៈកម្មាធិការវិនិយោគខេត្ត ។
- អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរី មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែក សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន ។

**មាត្រា៣:** អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគិរី ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគំរោងដែលមានទុនវិនិយោគទាបជាង០២(ពីរ) លានដុល្លារអាមេរិក ។

**មាត្រា៤:** អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគិរី ត្រូវផ្ដល់ឯកសារពាក់ព័ន្ធនឹងគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការពិនិត្យ និងផ្ដល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ ។

**មាត្រា៥:** គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ-អង្គភាពក្នុងខេត្តរតនៈគិរី ជាខ្សែបណ្ដោយរបស់ខ្លួន នូវសិទ្ធិសំរេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទប្បញ្ញត្តិណែនាំលំអិតដល់មន្ត្រីក្រោមឱវាទ ស្ដីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

**មាត្រា៦:** គំរោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសំរេចក្នុងការចុះបញ្ជីសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគិរីទេ ដោយត្រូវឆ្លងការចុះបញ្ជីក្រោមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការវិនិយោគកម្ពុជា :

១- គំរោងមានទំហំទុនវិនិយោគចាប់ពី ០២(ពីរ)លានដុល្លារអាមេរិកឡើងទៅ ។

២- គំរោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខេត្ត-ក្រុង ចាប់ពីពីរឡើងទៅ ។

៣- គំរោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

**មាត្រា៧:** នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្ដល់ការលើកទឹកចិត្តវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគិរី គឺ :

- ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការងារវិនិយោគនៅក្នុងខេត្ត
- ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទប្បញ្ញត្តិស្ដីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ ។

**មាត្រា៨:** ការវិនិយោគទាំងឡាយណា ដែលបានទទួលការអនុញ្ញាតដោយច្បាប់ ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវចាត់ទុកជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលអ្នកវិនិយោគបានបំពេញរាល់បែបបទតាមនីតិវិធីកំណត់ ដូចមានចែងក្នុងអនុក្រឹត្យ ស្ដីពីការណែនាំអនុវត្តច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៩:** - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញបទប្បញ្ញត្តិ ស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរី ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

- អនុគណៈកម្មាធិការវិនិយោគខេត្តរតនៈគីរី ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

**មាត្រា១០:** សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តរតនៈគីរី-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គាត ឈន់**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ